Khmer | ភាសាខ្មែរ

Australian Government

NATIONAL BOWEL CANCER SCREENING PROGRAM

# ព័ត៌មានអំពីការទទួល បានការឆ្លុះពិនិត្យមើល ផ្ទៃខាងក្នុងនៃ ពោះវៀនធំ



Interpreter

**សម្រាប់ព័ត៌មានជាភាសារបស់អ្នក**
សូមហៅទូរសព្ទទៅសេវាបកប្រែភាសាសរសេរ និងភាសាផ្ទាល់មាត់៖ 13 14 50 ឬចូលមើល
**www.health.gov.au/nbcsp-translations**

**ការធ្វើតេស្តពិនិត្យរកមើលជំងឺមហារីកពោះវៀនរបស់អ្នកបានរកឃើញឈាមនៅក្នុងលាមករបស់អ្នក។ វាអាចមានហេតុផលជាច្រើនដែលឈាមត្រូវបានរកឃើញ ភាគច្រើនមិនពាក់ព័ន្ធនឹងជំងឺមហារីកទេ ប៉ុន្តែវាសំខាន់ណាស់ក្នុងការស្វែងរកមូលហេតុនោះ។**

- ☐ **ធ្វើការណាត់ជួបដើម្បីពិភាក្សាអំពីលទ្ធផលតេស្តវិជ្ជមានរបស់អ្នកជាមួយវេជ្ជបណ្ឌិតរបស់អ្នក។** វេជ្ជបណ្ឌិតរបស់អ្នកអាចណែនាំឱ្យធ្វើតេស្តមួយហៅថា ការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ។

## អំពីការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ

ការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ គឺជានីតិវិធីដែលប្រើបំពង់បត់បែនស្តើង ដែលមានដាក់ភ្ជាប់កាមេរ៉ាតូចមួយហៅថា ឧបករណ៍ឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ (ឧបករណ៍ឆ្លុះ) ដើម្បីមើលខាងក្នុងពោះវៀនរបស់អ្នក។

វេជ្ជបណ្ឌិតនឹងផ្តល់ថ្នាំដើម្បីឱ្យអ្នកសម្រាកបន្ធូរ (ហៅថា ការសណ្តំ)។

ខណៈពេលដែលអ្នកកំពុងដេក វេជ្ជបណ្ឌិតនឹងបញ្ចូលឧបករណ៍ឆ្លុះតាមគូថរបស់អ្នក និងចូលទៅក្នុងពោះវៀនរបស់អ្នក ដើម្បីរកមើលដុំពក ឬសាច់ដុះ។

អ្នកនឹងមិនមានអារម្មណ៍ដឹងរឿងនោះ ឬដឹងពីអ្វីដែលកើតឡើងក្នុងអំឡុងពេលនៃការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំទេ។

នីតិវិធីត្រូវចំណាយពេលរហូតដល់ទៅ 45 នាទី។ អ្នកអាចរំពឹងថានឹងនៅមន្ទីរពេទ្យរយៈពេល 3 ទៅ 4 ម៉ោង។

អ្នកអាចជ្រើសរើសដើម្បីធ្វើការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំរបស់អ្នកនៅក្នុងមន្ទីរពេទ្យរដ្ឋ ឬមន្ទីរពេទ្យឯកជន ឬគ្លីនិកឯកជន។

## ហេតុអ្វីបានជាវេជ្ជបណ្ឌិតរបស់ខ្ញុំណែនាំឱ្យធ្វើការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ?

- ការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ គឺជាវិធីល្អបំផុតដើម្បីពិនិត្យរកមូលហេតុនៃការហូរឈាម។
- ក្នុងអំឡុងពេលនៃការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ វេជ្ជបណ្ឌិតនឹងកាត់ចេញដុំពក ឬសាច់ដុះដែលបានរកឃើញ។
- ដុំពក គឺជាសាច់ដុះតូចមួយដែលនៅភ្ជាប់នឹងជញ្ជាំងពោះវៀន ដែលជួនកាលអាចវិវត្តន៍ទៅជាជំងឺមហារីក។
- ការកាត់ដុំពកចេញអាចជួយទប់ស្កាត់ជំងឺមហារីក ហើយមិនមានការឈឺចាប់ទេ។
- ដុំពក ឬសាច់ដុះដែលបានកាត់ចេញត្រូវបានធ្វើតេស្តនៅមន្ទីរពិសោធន៍ដើម្បីមើលថាតើវាជាដុំពកគំរាមកំហែងជីវិត (ជំងឺមហារីក) ឬដុំពកដែលមិនលូតលាស់ (គ្មានគ្រោះថ្នាក់)។

## តើខ្ញុំត្រូវត្រៀមលក្ខណៈបែបណាសម្រាប់ការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ?

ប្រសិនបើអ្នកមានបញ្ហាសុខភាព ឬពិសាថ្នាំពេទ្យជាប្រចាំ សូមពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតរបស់អ្នក មុនពេលអ្នកចាប់ផ្តើមការត្រៀមរៀបការឆ្លុះពិនិត្យមើលវៀនរបស់អ្នក។ ពួកគេអាចប្រាប់អ្នកឱ្យឈប់ពិសាថ្នាំពេទ្យមួយចំនួនសម្រាប់រយៈពេលពីរបីថ្ងៃមុនពេលការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំរបស់អ្នក។

អ្នកនឹងត្រូវបានប្រាប់ពីរបៀបត្រៀមរៀបចំ ដែលទាក់ទងនឹង៖

- **របបអាហារ។** អ្វីខ្លះដែលត្រូវបរិភោគ និងផឹកនៅក្នុងប៉ុន្មានថ្ងៃមុនការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំរបស់អ្នក។
- **ការត្រៀមរៀបការឆ្លុះពិនិត្យវៀន។** របៀបទទួលបានកញ្ចប់ថ្នាំដែលនឹងធ្វើឱ្យអ្នកទៅបង្គន់ដើម្បីសម្អាតពោះវៀនរបស់អ្នក។

អ្នកត្រូវតែធ្វើតាមការណែនាំអំពីការត្រៀមរៀបចំពោះវៀនដោយប្រុងប្រយ័ត្ន ដើម្បីឱ្យវេជ្ជបណ្ឌិតអាចមើលឃើញនៅខាងក្នុងពោះវៀនរបស់អ្នក។ បើមិនដូច្នោះទេ អ្នកអាចត្រូវធ្វើការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំម្តងទៀត។

## តើមានអ្វីខ្លះកើតឡើងបន្ទាប់ពីការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ?

នៅពេលអ្នកក្រោកដឹងខ្លួនពីការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំហើយ អ្នកនឹងត្រូវបានគេផ្តល់អាហារ និងភេសជ្ជៈ។ អ្នកអាចមានអារម្មណ៍ថាហើមពោះបន្តិច ប៉ុន្តែវានឹងមានរយៈពេលប្រហែលតែមួយម៉ោងប៉ុណ្ណោះ។ អ្នកអាចហូរឈាមបរិមាណតិចតួច ប៉ុន្តែនេះគឺជារឿងធម្មតាទេ។

អ្នកនឹងត្រូវបានប្រាប់ពីរបៀបដែលវាបានដំណើរការ របៀបថែទាំខ្លួនអ្នកនៅពេលអ្នកទៅដល់ផ្ទះ ពេលណាត្រូវចាប់ផ្តើមរបបអាហារធម្មតា និងថ្នាំពេទ្យរបស់អ្នកឡើងវិញ និងការតាមដានណាមួយដែលចាំបាច់។ មិត្តភ័ក្តិ ឬសមាជិកគ្រួសារត្រូវតែនាំអ្នកទៅផ្ទះ ហើយស្នាក់នៅជាមួយអ្នក។

អ្នក និងវេជ្ជបណ្ឌិតរបស់អ្នកនឹងត្រូវបានផ្តល់នូវរបាយការណ៍មួយអំពីការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ និងលទ្ធផលតេស្តមន្ទីរពិសោធន៍ណាមួយ។

អ្នក ឬវេជ្ជបណ្ឌិតរបស់អ្នកគួរតែរាយការណ៍ពីលទ្ធផលមន្ទីរពិសោធន៍របស់អ្នកទៅបញ្ជីត្រួតពិនិត្យជំងឺមហារីកថ្នាក់ជាតិ។

ដោយសារតែអ្នកត្រូវបានគេផ្តល់នូវការសណ្តំ សម្រាប់រយៈពេល 24 ម៉ោងបន្ទាប់ពីការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំរបស់អ្នក នោះមិនត្រូវ៖

- បើករថយន្ត
- ធ្វើដំណើរតែម្នាក់ឯង
- ប្រើគ្រឿងម៉ាស៊ីន
- ចុះហត្ថលេខាលើឯកសារច្បាប់
- ផឹកគ្រឿងស្រវឹង។

## តើការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំមានភាពត្រឹមត្រូវយ៉ាងណាដែរ?

ការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំគឺមានភាពត្រឹមត្រូវណាស់ ហើយជាវិធីដ៏ល្អបំផុតដើម្បីរកឱ្យឃើញពីមូលហេតុដែលអ្នកទទួលបានលទ្ធផលតេស្តវិជ្ជមាន។ វានៅតែមានឱកាសតិចតួចដែលអ្វីមួយអាចមិនត្រូវបានឆ្លុះរកឃើញក្នុងអំឡុងពេលនៃនីតិវិធីរបស់អ្នក។

ប្រសិនបើគ្មានជំងឺមហារីក ឬដុំពកត្រូវបានរកឃើញទេ អ្នកគួរតែបន្តការពិនិត្យជាមួយនឹងកម្មវិធីពិនិត្យជំងឺមហារីកពោះវៀនថ្នាក់ជាតិ។ នៅពេលជិតដល់ពេលការពិនិត្យបន្ទាប់ទៀត យើងនឹងផ្ញើឱ្យអ្នកនូវការធ្វើតេស្តមួយទៀត។

## តើមានហានិភ័យ ឬផលប៉ះពាល់អ្វីទេ?

ផលប៉ះពាល់បន្ទាប់ពីការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំគឺមិនមានជាទូទៅទេ។ អ្នកអាចនឹងមានការឈឺក្បាល ឬក្អួតដោយសារការត្រៀមរៀបចំពោះវៀន ឬមានហូរឈាមក្រោយការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ។ អ្នកអាចមានប្រតិកម្មចំពោះការសណ្តំ ប៉ុន្តែរឿងនេះកម្រណាស់។ វាកម្រណាស់ដែលមនុស្សខ្លះត្រូវចូលទៅមន្ទីរពេទ្យវិញ។

អ្នកគួរតែពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតរបស់អ្នកអំពីហានិភ័យ ឬការព្រួយបារម្ភណាមួយ នៅមុនការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំរបស់អ្នក។

## តើមានការចំណាយលើការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំដែរឬទេ?

ក្នុងនាមជាអ្នកជំងឺសាធារណៈនៅក្នុងមន្ទីរពេទ្យរដ្ឋ មិនមានការចំណាយលើការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំទេ។ ក្នុងនាមជាអ្នកជំងឺឯកជន អ្នកអាចត្រូវបង់ប្រាក់ ប្រសិនបើអ្នកធ្វើការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ អាស្រ័យលើការធានារ៉ាប់រងសុខភាពឯកជនរបស់អ្នក។ អ្នកអាចត្រូវបង់ប្រាក់សម្រាប់កញ្ចប់ត្រៀមរៀបចំការឆ្លុះពិនិត្យពោះវៀន។

## សំណួរ?

ខិត្តប័ណ្ណនេះអាចជួយអ្នកឱ្យយល់ដឹងអំពីនីតិវិធីនៃការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ។ វេជ្ជបណ្ឌិត ឬមន្ទីរពេទ្យរបស់អ្នកអាចផ្តល់ឱ្យអ្នកនូវព័ត៌មានបន្ថែមទៀត។

DT0004036 - 0825

ស្វែងយល់បន្ថែមអំពីកម្មវិធីពិនិត្យរកមើលជំងឺមហារីកពោះវៀនថ្នាក់ជាតិ

**www.health.gov.au/nbcsp.**